# មេរៀនទី ៦០: ពួកសិស្សដើរតាមព្រះយេស៊ូវ

## ម៉ាកុស ១:១៤-២០

**គោលបំណង៖** ដើរតាមព្រះយេស៊ូវ។

**ខគម្ពីរចងចាំ៖ ម៉ាកុស ១:១៧** *“ទ្រង់មានព្រះបន្ទូលហៅថា ចូរមកតាមខ្ញុំ ខ្ញុំនឹងតាំងឲ្យអ្នកនេសាទមនុស្សវិញ”*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ព្រះយេស៊ូវត្រាស់ហៅយើងឲ្យដើរតាមទ្រង់និងធ្វើជាអ្នកនេសាទមនុស្ស។ ក្នុងនាមជាគ្រូសាលាថ្ងៃអាទិត្យ អ្នកគឺបានបំពេញកាតព្វកិច្ចទាំងពីរនេះរួចហើយ! គឺអ្នកបានដើរតាមព្រះយេស៊ូវ និងធ្វើការជាអ្នកនេសាទមនុស្សតាមរយៈការចែកចាយដំណឹងល្អទៅដល់កុមារតូចៗ! នៅថ្ងៃនេះ សូមឲ្យអ្នកបានអធិស្ឋានទៅកាន់ព្រះដើម្បីទូលសូមនូវសេចក្តីជំនឿក្នុងការបន្តដំណើរជាមួយទ្រង់ និងប្រាជ្ញាក្នុងការបង្រៀនកុមារអំពីសេចក្តីស្រលាញ់របស់ព្រះអង្គ។

**ចំរៀង៖** ១. ខ្ញុំបានសម្រេចចិត្ត ២. ខ្ញុំដើរតាមព្រះយេស៊ូវ ៣. ពេត្រុសអើយ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «ធ្វើតាមខ្ញុំ»



១.សូមជ្រើសរើសសិស្ស ២-៣នាក់ ហើយឲ្យពួកគេឡើងមកខាងមុខដើម្បីធ្វើជាអ្នកធ្វើកាយវិការ។

២.ឲ្យកុមារធ្វើជាអ្នកដឹកនាំ(ម្តងម្នាក់) ដោយឲ្យគេធ្វើកាយវិការអ្វីមួយហើយឲ្យអ្នកផ្សេងទៀតធ្វើតាម។ អាចជាការ ឈរជើងមួយ ធ្វើកាយវិកាយបក្សី រមៀលលើឥដ្ឋ ឬក៏ធ្វើអ្វីផ្សេងទៀតដែលអាចឲ្យកុមារដទៃធ្វើតាមបាន។

៣. សូមឲ្យកុមារដែលជាអ្នកដឹកនាំផ្សេងទៀតធ្វើកាយវិការផ្សេងម្តង ។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា វាមិនមែនជារឿងងាយស្រួលនោះទេក្នុងការដើរតាមអ្នកដឹកនាំ ប៉ុន្តែយើងត្រូវតែព្យាយាមឲ្យអស់ពីសមត្ថភាពក្នុងការដើរតាមអ្នកដឹកនាំដ៏ពិតរបស់យើងគឺជាព្រះយេស៊ូវគ្រីស្ទ!

### ៤. ការណែនាំមេរៀន

គ្រូសូមនាំកុមារដើរនៅក្នុងថ្នាក់រៀន ដោយឲ្យពួកគេដើរពីក្រោយគ្រូជាជួរ គ្រូដើរផងស្រែកប្រាប់កុមារផង បើគ្រូស្រែកថា ដើរលឿនកុមារត្រូវឲ្យលឿន បើគ្រូស្រែកថាដើរមួយៗកុមារត្រូវដើរមួយៗ គ្រូស្រែកថាឈប់ពួកគេត្រូវឈប់ដើរ គ្រូស្រែកថា ដំណើរស្វាកុមារត្រូវដើរដំណើរដូចសត្វស្វា ហើយបើគ្រូនិយាយថាដំណើរទា ពួកគេត្រូវដើរដំណើរទា។ គ្រូត្រូវផ្លាស់ប្តូរដំណើរឱ្យលឿនដើម្បីឱ្យកុមារឆាប់ហត់ ពេលកុមារហត់សូមឱ្យពួកគេអង្គុយចុះ។ គ្រូ

និយាយទៅកុមារថា នៅថ្ងៃនេះព្រះយេស៊ូវបានត្រាស់ហៅបុរសមួយចំនួនក្នុងការដើរតាមទ្រង់។ តោះ! សូមឲ្យយើងបានស្វែងយល់ពីរបៀបដែលពួកគាត់បានឆ្លើយតបជាមួយនឹងព្រះយេស៊ូវ!



## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងនៅថ្ងៃនេះ គឺនិយាយពីព្រះយេស៊ូវបានជួបជុំពួកសាវករបស់ទ្រង់។ ពួកសាវកគឺដូចជាសិស្សអីចឹង ហើយជំនាន់នោះ ពួកសិស្សបានព្យាយាមស្វែងរកគ្រូក្នុងការរៀនសូត្រនូវអ្វីដែលថ្មី។ ប៉ុន្តែនៅក្នុងសាច់រឿងនេះ ព្រះយេស៊ូវជាអ្នកដែលស្វែងរកសិស្សទៅវិញ។

ព្រះអង្គបានជ្រើសរើសសិស្សរបស់ទ្រង់មួយចំនួនដែលជាអ្នកនេសាទត្រី។ ព្រះយេស៊ូវបានមករកពួកគេនៅពេលដែលពួកគេកំពុងនេសាទត្រី ហើយទ្រង់បានហៅពួកគេឲ្យដើរតាមទ្រង់វិញ។ ព្រះអង្គបានមានបន្ទូលថា ពួកគេនឹងនេសាទមនុស្សវិញម្តង! ស្តាប់ទៅវាដូចជាចម្លែកបន្តិចមែនអត់? ប៉ុន្តែសូមឲ្យយើសាកទាយទៅមើលថា តើពួកសិស្សបានធ្វើអ្វី? ពួកសិស្សមិនបានសុំឲ្យព្រះយេស៊ូវរង់ចាំពួកគេនេសាទរួចសិននោះទេ។ ពួកគេមិនបានសួរព្រះយេស៊ូវទេថា តើទ្រង់ចង់សំដៅទៅលើអ្វីអំពីការនេសាទមនុស្សនោះ។ នៅក្នុងព្រះគម្ពីរបានចែងថា “ រំពេចនោះ” ពួកសិស្សបានទំលាក់អួនចុះហើយដើរតាមព្រះយេស៊ូវ។

ពួកសិស្សមិនបានដឹងថាជីវិតរបស់ពួកគេនឹងទៅជាយ៉ាងណានោះទេ។ គេក៏មិនដឹងថាលោកគ្រូរបស់ពួកគេនឹងត្រូវស្លាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខទៀតនោះដែរ ឬក៏សមាជិករបស់ពួកគេអាចនឹងត្រូវស្លាប់ដោយព្រោះតែសេចក្តីជំនឿចំពោះព្រះជាម្ចាស់ឡើយ។ ប៉ុន្តែពួកគេដឹងថា ការដែលដើរតាមព្រះយេស៊ូវពិតជាមានសារៈសំខាន់ខ្លាំងណាស់ ហើយនោះវាគឺជាអ្វីដែលពួកគាត់ត្រូវតែធ្វើ។ ពួកគាត់សុខចិត្តប្រថុយប្រថាន ដោយការទម្លាក់ចោលនូវកិច្ចការផ្សេងៗ ហើយចំណាយពេលតែជាមួយនឹងព្រះមេស្ស៊ីតែប៉ុណ្ណោះក្នុងកំឡុងពេលដែលពួកគេអាចធ្វើវាបាន។ ពួកគេដឹងថាការធ្វើបែបនេះគឺពិតជាមានន័យជាជាងកិច្ចការទាំងអស់ដែលពួកគេកំពុងធ្វើ។

ហើយចុះពួកយើងវិញ? ពួកយើងត្រូវតែទុកព្រះជាម្ចាស់ជាជម្រើសដំបូងបំផុតនៅក្នុងជីវិតរស់នៅរបស់ពួកយើង យើងត្រូវតែហ៊ានលះបង់នូវរបស់មួយចំនួនដើម្បីឲ្យយើងអាចបម្រើទ្រង់អស់ពីចិត្តរបស់ពួកយើង។ តើអ្នកដឹងទេ? វាពិតជាមានតម្លៃណាស់! ជីវិតដើរតាមព្រះយេស៊ូវគឺមានតម្លៃជាងអ្វីទាំងអស់ដែលយើងអាចធ្វើឬក៏ស្រម៉ៃអំពីវា។ ការដើរតាមព្រះយេស៊ូវវាមិនងាយស្រួលរហូតនោះទេ ប៉ុន្តែទ្រង់បាននាំមកឲ្យយើងនូវសេចក្តីអំណរ សន្តិភាព និងជីវិតអស់កល្បយ៉ាងពិតប្រាកដ។ ព្រះយេស៊ូវបានសន្យាថាទ្រង់នឹងនៅជាមួយយើង និងផ្តល់នូវអ្វីដែលយើងត្រូវ-ការ។ ព្រះអង្គប្រើយើងជាអ្នកចែករំលែកសេចក្តីស្រលាញ់និងដំណឹងល្អរបស់ទ្រង់។ ដូច្នេះសូមឲ្យយើងមានជំនឿលើទ្រង់។ ជឿលើសេចក្តីបង្រៀនរបស់ព្រះអង្គ ហើយត្រូវតែត្រៀមខ្លួនរួចជាស្រេចក្នុងការស្តាប់បង្គាប់និងដើរតាមព្រះយេស៊ូវ។ វាគឺពិតជាមានតម្លៃខ្លាំងណាស់។

## ៦. សំនួរពិភាក្សា

១. តើសាវកគឺជាអ្វី? *សិស្ស*

២.តើពួកអ្នកនេសាទត្រីធ្វើដូចម្តេចនៅពេលដែលព្រះយេស៊ូវត្រាស់ហៅពួកគេឲ្យដើរតាមទ្រង់?
*ពួកគេបានដើរតាមទ្រង់មួយរំពេច*

៣. តើព្រះយេស៊ូវបានមានបន្ទូលថានឹងបង្រៀនពួកគេឲ្យធ្វើអ្វី?*អ្នកនេសាទមនុស្ស*

៤. តើអ្នកគិតថាការនេសាទមនុស្សមានន័យដូចម្តេច? *បង្រៀនអ្នកដទៃអំពីព្រះយេស៊ូវ*

៥. ព្រះយេស៊ូវបានត្រាស់ហៅយើងគ្រប់គ្នាឲ្យដើរតាមព្រះអង្គនៅថ្ងៃនេះ។ តើអ្នកនឹងឆ្លើយដូចម្តេច?
*ទុកឲ្យកុមារជាអ្នកឆ្លើយ*

## ៧. ល្បែងកំសាន្ត «បង់សំណាញ់»



១. ព្រះយេស៊ូវចង់ឲ្យយើងក្លាយទៅជាអ្នកនេសាទមនុស្ស។ នេះគឺមានន័យថា យើងត្រូវតែ “ឈោងចាប់” មនុស្សដោយសេចក្តីស្រលាញ់របស់ព្រះយេស៊ូវ ដូច្នេះពួកគេអាចមកទទួលជឿព្រះយេស៊ូវបាន។

២. ចែកកុមារជា ២ក្រុម ដោយមួយក្រុមដើរតួជាសំណាញ់ ហើយមួយក្រុមទៀតដើរតួជាត្រី។

៣. ក្រុមដែលដើរតួជាសំណាញ់ត្រូវឈរជារង្វង់ហើយកាន់ដៃគ្នាហើយលើកឡើងលើ។

៤. ក្រុមត្រីត្រូវហែលចេញនិងចូលក្នុងរង្វង់ ប៉ុន្តែនៅពេលដែលគ្រូស្រែកថា “ចាប់ត្រី” ក្រុមសំណាញ់ត្រូវទំលាក់ដៃចុះក្រោម ដើម្បីកុំឲ្យត្រីហែលចេញពីក្នុងរង្វង់បាន។

## ៨. ខគម្ពីរចងចាំ ម៉ាកុស ១:១៧

## ៩. ហត្ថកម្ម «តោះចាប់ត្រី!»

**សម្ភារៈដែលត្រូវការៈ**សូមបោះពុម្ពរូបអ្នកនេសាទជាមួយអួន(ទំព័រខាងក្រោម) ក្រដាសពណ៌ កន្រ្តៃ និង ការបិត

១. សូមឲ្យក្រដាសរូបភាពអ្នកនេសាទជាមួយអួនទៅកុមារគ្រប់ៗគ្នាម្នាក់មួយសន្លឹក។

២. ឲ្យក្រដាសពណ៌ទៅកុមារគ្រប់ៗគ្នា ហើយឲ្យពួកគេកាត់ចេញជារូបត្រីតូចៗហើយបិទភ្ជាប់ជាមួយអួន។

៣. សូមរំលឹកកុមារថា ព្រះយេស៊ូវចង់ឲ្យយើងដើរតាមទ្រង់ និងធ្វើជាអ្នកនេសាទមនុស្សសម្រាប់ទ្រង់។





**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# តោះ!ចាប់ត្រី



**ម៉ាកុស ១៖១៧**“*ទ្រង់មានព្រះបន្ទូលហៅថា ចូរមកតាមខ្ញុំ ខ្ញុំនឹងតាំងឲ្យអ្នកនេសាទមនុស្សវិញ*”